ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ០៧៤៦ អពដ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន ១០០នាក់ ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជូនដំណឹងដល់និស្សិត នៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ជ្រាបថា៖ អគ្គនាយកដ្ឋានពន្ធដារត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្ត ចំនួន ១០០នាក់ ដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចុះធ្វើការអង្កេត(Street Survey) និងប្រមូលព័ត៌មានសហគ្រាស ដែលកំពុងមានសកម្មភាពអាជីវកម្មនៅភូមិសាស្ត្រ នៅរាជធានី ខេត្ត-ខណ្ឌនីមួយៗ ។

លក្ខខណ្ឌនៃការជ្រើសរើស៖

- បេក្ខជនជានិស្សិតចាប់ពីឆ្នាំទី៣ឡើងទៅ នៅតាមគ្រឹះស្ថានឧត្តមសិក្សានានានៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ។
- ត្រូវមានជំនាញពន្ធដារ គណនេយ្យ ផែនការនិងស្ថិតិ សេដ្ឋកិច្ច គ្រប់គ្រង ទីផ្សារ ធនាគារ និងហិរញ្ញវត្ថុ និងអក្សរសាស្ត្រអង់គ្លេស ។
- មានឆន្ទៈក្នុងការបំពេញការងារ យ៉ាងមោះមុត ។

សំគាល់ សូមភ្ជាប់មកជាមួយនូវ៖

- ជីវប្រវត្តិសង្ខេប (មានបិទរូបថត ៤x៦) ចំនួន ១ច្បាប់
- សេចក្តីចម្លងលិខិតបញ្ជាក់ការសិក្សា ចំនួន ១ច្បាប់
- ពាក្យស្នើសុំចូលបម្រើការងារដោយស្ម័គ្រចិត្ត ចំនួន ១ច្បាប់

អាស្រ័យហេតុនេះបើបេក្ខជនមានបំណងស្ម័គ្រចិត្តចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៤ រហូតដល់ ថ្ងៃទី៣០ ខែមេសាឆ្នាំ២០១៤ រៀងរាល់ម៉ោងធ្វើការ ។

ទំនាក់ទំនងអាសយដ្ឋាន៖ អាគារកែងមហាវិថី (១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ៨៨៦ ៧២៤
០១២ ២៧៦ ៦២៩
០១២ ៩០៦ ៧៨៤
០១២ ៦៦៧ ១៨៨

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤

អគ្គនាយកដ្ឋានពន្ធដារ